គំរោងស្តារឡើងវិញ លើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច នៅបណ្តាខេត្តនៃតំបន់ពាយ័ព្យ (អេកូសន)

Economic and Social Relaunch of Northwest Provinces (ECOSORN)

Agricultural Development – Training and Business Development – Community Empowerment – Safeguarding Land – Rural Infrastructure – Integrated Rural Development

ព្រឹត្តិប័ត្រព័ត៌មានអេកូសន លេខទី៨ - កញ្ញា ឆ្នាំ២០១០

ECOSORN Newsletter, Issue 8 - September 2010

# ក្រុមផលិតស្រូវពូជជួយគ្រួសារក្នុងសហគមន៍

# RICE SEED PRODUCTION GROUPS HELP COMMUNITY FAMILIES

ភូមិព្រៃសង្ហា : ជាមួយម៉ាស៊ីនបោកស្រូវមួយគ្រឿង លោក ហ៊ុល ខ្លឹម និងភរិយា ដោយរួមទាំងកសិករមួយចំនួនទៀតអាចបោកស្រូវបានយ៉ាងរហ័សជាងមុន។ ម៉ាស៊ីនបោកស្រូវនេះ ផ្តល់ដោយគម្រោងអេកូ-សន។ សម្ភារដទៃទៀតរួមមានកង្ហាររោយស្រូវ សំពត់តង់ និងម៉ាស៊ីនដេរមាត់ការុង ដោយរួមទាំងពូជស្រូវផងដែរ។ ការផ្តល់កញ្ចប់សម្ភារទាំងនេះគឺធ្វើឡើងតាមរយៈក្រុមផលិតស្រូវពូជ ដែលបានបង្កើតឡើងដោយក្រុមគ្រួសារគំរូនៅក្នុងសហគមន៍មូលដ្ឋាន។

ក្រុមផលិតស្រូវពូជនេះ ពិតជាមានសារៈសំខាន់បំផុត ដែលធ្វើឱ្យសមាជិកមានជីវភាពប្រសើរជាងមុននេះ បើតាមការបញ្ជាក់របស់លោក ហ៊ុល ខ្លឹម កសិករម្នាក់អាយុ ៥៤ឆ្នាំ ដែលរស់នៅក្នុងភូមិព្រៃសង្ហា ស្រុកបវេល ខេត្តបាត់ដំបង។ លោក ខ្លឹម បាននិយាយថា "ក្រុមផលិតស្រូវពូជនេះបានបង្កើតឡើងតាមរយៈការផ្តល់យោបល់ និងបច្ចេកទេសពីអ្នកម៉ៅការរបស់គម្រោងអេកូសន។ លោក ខ្លឹម បានបន្ថែមថា សមាជិកនៅក្នុងក្រុមនេះ គឺត្រូវបានជ្រើសរើសឱ្យធ្វើជាកសិករគំរូ ដើម្បីផលិតស្រូវពូជ នៅក្នុងភូមិរបស់យើង"។

ដោយមានទឹកមុខញញឹមបន្តិច លោក ខ្លឹមបាននិយាយបន្ថែមថា ស្រូវពូជលក់បាន

តទៅទំព័រទី ២



កសិករ ហ៊ុល ខ្លឹម កំពុងបោកស្រូវ


## មាតិកា

ក្រុមផលិតស្រូវពូជជួយគ្រួសារក្នុងសហគមន៍..............១

ដីសុវត្ថិភាព ជីវិតសុខសាន្ត និង ការអភិវឌ្ឍសហគមន៍..... ៣

បំណិនជីវិតជួយជីវភាពគ្រួសារ.................................៥

បង្គន់អនាម័យនៅតាមសហគមន៍.............................៦

ថែរក្សាប្រឡាយទឹកដើម្បីជីវភាពប្រចាំថ្ងៃ.................៧

សិក្ខាសាលាប្រចាំឆ្នាំពិនិត្យមើលលើសមិទ្ធផល និងការរៀបចំផែនការថ្មី នៅបាត់ដំបង.....................៨

## CONTENTS

Rice seed production groupshelp community family........................................1

Safe land, safe life and community development........................................3

Life skill helps family........................................5

Hygiene tolet in communities........................................6

Canal maintenance for daily life........................................7

Annual workshop to overview achievements and new planning in Battambang........................8


Prey Sangha Village : With a threshing machine, Hul Khlem and his wife, including some other villagers, can thresh rice faster than before. The threshing machine was provided by ECOSORN.

The other tools are big fan, tents and sack sawing machine including rice seeds. Providing the package of tools has been done through the Rice Seed Production Group established by the pilot farmers in the local communities.

The Rice Seed Production Group is so important to improve its members' living condition, according to Hul Khlem, a 54-year-old farmer living Prey Sangha village of Bttambnang province's Bovel district. "This Rice Seed Production Group has created under the technical advice of ECOSORN's contractor. The group members have been selected to be the pilot farmers in order to produce rice seeds in our village," Khlem said.

With the a bit smiling face, Khlem added that the price of rice seed higher than the price of normal rice but not everyone can plant the rice seeds because the seeds need new technique for high quality of yields and the group members have learnt the technical knowledge from the project.

Prey Sangha has 20 families who are the members of the Rice Seed Production Group and 30 percent of their total rice fields have been grown the rice seeds.

Khlem affirmed that this year he has saved some money from the rice seed yields and bought a motorbike for his children for riding to school and for the family's use and that he has noted other members of the group now also have their better living conditions than before.

Kim Kim Leang, ECOSORN Project Coordinator based in Battambang, said "ECOSORN's technical team members and I very often come to the target areas, especially at the seasons of growing rice plants and collecting the rice yields to make sure if the pilot farmers implemented in accordance with the new technique and to identify their challenges in order to find solutions," she said.

She expressed her satisfying that the pilot farmers now in the target areas have their better living condition than before and other farmers who are not the direct beneficiaries also starting to repeat the good model of new technology such as SRI- animal raising-vegetable planting through advice of village master farmers.

The three-year project of ECOSORN in 2008-2010 has

continued on page 2



គំរោងនេះប្រតិបត្តិដោយគំរោងអេកូសន និងផ្តល់មូលនិធិដោយសហភាពអឺរ៉ុប និងរាជរដ្ឋាភិបាលកម្ពុជា

# ក្រុមផលិតស្រូវពូជជួយគ្រួសារ...

## RICE SEED PRODUCTION GROUPS HELP ...

តម្លៃថ្លៃជាងស្រូវសម្រាប់ហូប ប៉ុន្តែមិនមែនអ្នកគ្រប់គ្នាអាចដាំស្រូវពូជបានទាំងអស់គ្នានោះទេ ព្រោះវាត្រូវការការថែទាំតាមបែបបច្ចេកទេសថ្មីដើម្បីឱ្យវាមានគុណភាពខ្ពស់ ហើយសមាជិកក្រុមបានរៀនសូត្រចំណេះដឹងបច្ចេកទេសថ្មីនេះពីគម្រោងអេកូសន។

ភូមិព្រៃសង្ហាមានចំនួន២០គ្រួសារជាសមាជិកនៃក្រុមផលិតស្រូវពូជនេះ ហើយផ្ទៃដីស្រែចំនួន ៣០% ក្នុងចំណោមផ្ទៃដីសរុបរបស់សមាជិកទាំងនេះ ត្រូវបានដាំដុះស្រូវពូជ។

លោក ខ្លឹម បានអះអាងថា ឆ្នាំនេះលោកបានសន្សំប្រាក់ ពីការលក់ផលស្រូវពូជនេះ ហើយទិញបានម៉ូតូមួយគ្រឿងឱ្យកូនជិះទៅរៀន និងសម្រាប់ប្រើប្រាស់ទៅតាមសេចក្តីត្រូវការរបស់គ្រួសារ លោកសង្កេតឃើញថាសមាជិកផ្សេងទៀត នៅក្នុងក្រុមរបស់លោកក៏មានជីវភាពគ្រាន់បើជាងមុនដែរ។

លោកស្រី គឹម គឹមលាង ប្រធានសម្របសម្រួលគម្រោងអេកូសនប្រចាំនៅខេត្តបាត់ដំបងបាននិយាយថា "ខ្ញុំ និង ក្រុមការងារបច្ចេកទេសបានមកកាន់តំបន់គោលដៅជាញឹកញាប់ ពិសេសនៅពេលរដូវសាបព្រួស ដកស្ទូង និងរដូវប្រមូលផល ដើម្បីប្រាកដថាកសិករគំរូបានអនុវត្តតាមបច្ចេកទេសថ្មី ឬក៏អត់ហើយស្វែងយល់ពីការ ប្រឈមរបស់ពួកគាត់ដើម្បីរកដំណោះស្រាយ"។

លោកស្រីបានសម្តែងការពេញចិត្តដែលកសិករគំរូនៅក្នុងតំបន់គោលដៅមានជីវភាពប្រសើជាងមុនហើយកសិករដទៃទៀតដែលមិនមែនជាអ្នកទទួលផលដោយផ្ទាល់ពីគម្រោង ក៏ចាប់ផ្តើមយកគំរូតាមអ្វីដែលគម្រោងអេកូសនបានអនុវត្តកន្លងមក លើការងារកសិកម្មដូចជាការចិញ្ចឹមសត្វ ការដាំស្រូវ និងដំណាំបន្លែ តាមរយៈគ្រូបង្គោលកសិកម្មតាមភូមិផងដែរ។

គម្រោងអេកូសនក្នុងរយៈពេលបីឆ្នាំគឺ ២០០៨-២០១០ បានបង្កើតក្រុមផលិតស្រូវពូជចំនួនពីរ នៅក្នុងតំបន់គោលដៅរបស់ខេត្តបាត់ដំបងដែលមានសមាជិកចំនួន ៣៥ គ្រួសារ ពីរក្រុមនៅខេត្តបន្ទាយមានជ័យ ដែលមានសមាជិកចំនួន ៣៤គ្រួសារ និងពីរក្រុមទៀត ដែលមានសមាជិកចំនួន ៤០ គ្រួសារ នៅខេត្តសៀមរាប។

បើតាមផែនការ ដែលបានគ្រោងទុក គឺនៅខេត្តបាត់ដំបងត្រូវផលិតឱ្យបានស្រូវពូជចំនួន ៨៥ តោន លើផ្ទៃដី ចំនួន ២១ ហិកតា ខេត្តបន្ទាយ-មានជ័យ ចំនួន ១៣ តោនលើផ្ទៃដី ៧,៥ ហិកតា និង ៣៣ តោន លើផ្ទៃដីចំនួន១៦ហិកតានៅខេត្តសៀមរាប។ យោងតាមរបាយការណ៍រីកចំរើនលើកទី ៧ របស់អេកូសនបានឱ្យដឹងថាដីស្រែរហូតដល់ ៤,៣០០ ហិកតាត្រូវដាំស្រូវពូជនៅឆ្នាំ ២០១០ នេះ ហើយត្រូវចំណាយពូជចន្លោះពី ៣០ គីឡូ ទៅ ៣៥គីឡូ ក្នុងមួយហិកតា។

បើតាមការឱ្យដឹងរបស់កសិករ ហ៊ុល ខ្លឹម បានបង្ហាញថាទិន្នផលស្រូវពូជពី ៦០ ភាគរយ ទៅ ៧០ ភាគរយ បានលក់នៅក្នុងភូមិតែម្តងក្នុងតម្លៃ ១.៨០០ រៀល ក្នុងមួយគីឡូក្រាម ហើយក្រៅពីនោះគឺលក់នៅទីផ្សារខាងក្រៅ ក្នុងតម្លៃដុំ១.៥០០ រៀល ក្នុងមួយគីឡូក្រាម និងលក់រាយក្នុងតម្លៃ ២.០០០ រៀល ក្នុងមួយគីឡូក្រាម។ ប្រភេទស្រូវពូជមាន ផ្ការំដួល ផ្ការំចង់ សែនពិដោរ អ៊ីអ៊ែរ ៦៦ រាំងជ័យ និងសែនក្រអូប ហើយពូជដែលបានលក់ថ្លៃជាងគេគឺប្រភេទរំដួល និងប្រភេទសែនក្រអូប។

ដើម្បីធ្វើឱ្យក្រុមផលិត ស្រូវពូជអាចដំណើរការបានប្រកបដោយនិរន្តរភាព បន្ទាប់ពីគម្រោងអេកូសនបានបញ្ចប់ក្រុមផលិតស្រូវពូជបានមានផែនការរៃអង្គាសប្រាក់ពីសមា-ជិករបស់ខ្លួន ហើយប្រាក់នេះរក្សាទុកដើម្បីជួសជុលម៉ាស៊ីនបោកស្រូវរួមរបស់ក្រុម។

លោក ហ៊ុល ខ្លឹម បាននិយាយថា "គម្រោងអេកូសន បានបង្រៀនពួកយើងឱ្យចេះដើរ ហេតុនេះយើងត្រូវតែដើរ ព្រោះយើងដឹងថា ការដើរនេះមានផលប្រយោជន៍ដល់ពួកយើងជាកសិករ។ ហេតុនេះយើងត្រូវបន្តឱ្យក្រុមស្រូវពូជរបស់យើងមាននិរន្តរ-ភាពបើទោះជាគម្រោងបានបញ្ចប់នៅចុងឆ្នាំ ២០១០នេះក៏ដោយ"។

លោកខ្លឹមបានបន្តថា "ដោយមើលឃើញបានផលចំណេញ ទើបកសិករនៅក្នុងភូមិខ្ញុំខ្លះទៀតបានសម្រេចដាំស្រូវពូជខ្លះដែរ ហើយខ្ញុំរីករាយនឹងចែករំលែកបទពិសោធន៍ និងចំណេះរបស់ខ្ញុំ ដែលទទួលបានពីគម្រោងអេកូសនដល់ពួកគេ។ បើកសិករនៅក្នុងភូមិរបស់ខ្ញុំមានជីវភាពសមរម្យសហគមន៍ក៏រុងរឿង ហើយប្រទេសជាតិក៏សម្បូណ៌សប្បាយដែរ"។



ភរិយា កសិករ ហ៊ុល ខ្លឹម កំពុងដេរបាវ

established two rice seed production groups with 35 families in its target areas of Battambang province, two groups with 34 families in Banteay Meanchey, and two other groups with 40 families in Siem Reap province.

According to the plan, Battambang must produce 85 tones of rice seeds on the total of 21 hectares of rice fields, 13 tones on 7.5 hectares in Banteay Meanchey, and 33 tones on 16 hectares in Siem Reap. Based on the 7th Progress Report of ECOSORN, up to 4.300 hectares of rice fields have been grown the rice seeds in 2010 and spent between 30 kg and 35 kg of the seed per hectare.

According to Hul Khlem, the rice seed yields from 60 percent to 70 percent has been sold in the village with the price of 1,800 riels per kilogram and the rest has been sold at the market with the whole sale of 1,500 riels per kilogram and 2,000 riles for retailing. The types of rice seeds are Phkar Rumdoul, Phkar Rumchang, Senpidor, IR66, Raing Chey, and Sen Kra-0up and the price of Phkar Rumdoul and Sen Kra-0up is more expressive.

To keep the sustainability of the Rice Seed Production Groups after the end of ECOSORN, the members of the groups have plan to take money from their members and the money is kept for repairing their collective rice threshing machine.

"ECOSORN project has taught us how to walk so that we have to walk because we know that the walk provides benefits to us as the farmers. That is why we must continue and sustain our group though the project is ended by the end of 20101," Hul Khlem said.

"Seeing the benefits, some other farmers in my village have also decided to grow rice seeds and I am pleased to share them the experience and knowledge I gained from ECOSORN. If the farmers in my village have good living condition, the communities are prosperous and the nation is also progressing and happy," Hul Khlem said.



This project is implemented by ECOSORN and funded by the European Union and the Royal Government of Cambodia
The views expressed in this publication do not necessarily reflect the views of the European Union

# ដីសុវត្ថិភាព ជីវិតសុខសាន្ត និង ការអភិវឌ្ឍសហគមន៍

# SAFE LAND, SAFE LIFE AND COMMUNITY DEVELOPMENT



ក្រុមដោះមីនស៊ីម៉ាក់កំពុងបោសសំអាតមីន

ភូមិតាថុកៈ ការរស់នៅក្នុងភូមិមួយដែលជាអតីតសមរភូមិរវាងទ័ពរដ្ឋាភិបាល និងពួកឧទ្ទាមខ្មែរក្រហមនោះ អ្នកស្រី ជា ផូ វ័យ ៤៦ ឆ្នាំ បាននិយាយថាគាត់និង អ្នកភូមិដទៃៗទៀតនាពេលបច្ចុប្បន្ននេះមាន អារម្មណ៍ថាមានសុវត្ថិភាពបន្ទាប់ពីដីចម្ការរបស់ខ្លួនត្រូវបានបោសសំអាតមីនរួច។

ស្ទើរតែគ្រប់កន្លែងក្នុងភូមិតាថុកដែលស្ថិតនេបណ្តោយជើងភ្នំ ត្រូវបានដាក់ស្លាកសញ្ញាគ្រោះថ្នាក់គ្រាប់មីន។ អ្នកស្រីជាផូបានរាយការណ៍ថាកាលពីបីឆ្នាំមុននេះអ្នកភូមិជាស្ត្រីម្នាក់ដែលបានដើរចូលក្នុងចម្ការរបស់គាត់បានស្លាប់ដោយសារជាន់មីនបន្ទាប់ពីនោះមក អ្នកស្រី ជា ផូ និងសមាជិកគ្រួសាររបស់គាត់ដទៃៗទៀត មិនដែលហ៊ានដើរចូលក្នុងចម្ការរបស់ខ្លួនទេ រហូតដល់មានអ្នកដោះមីនមួយក្រុមរបស់ គំរោងអេកូសន-មជ្ឈមណ្ឌល កំចាត់មីនកម្ពុជា (ស៊ីម៉ាក់) មកជួយបោសសម្អាតគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះនៅតំបន់នោះ។

សព្វថ្ងៃ អ្នកស្រី ជា ផូ មានកូនបីនាក់នៅក្នុងបន្ទុកបាននិយាយថា "ឥឡូវនេះខ្ញុំត្រេកអរខ្លាំងណាស់លើដីរបស់ខ្ញុំលែងមានគ្រាប់មីនហើយ ហើយក៏នឹងមិនមាននរណាម្នាក់ត្រូវស្លាប់ឬក៏របួសដោយសារវាទៀតដែរនៅលើដីរបស់ខ្ញុំ និងនៅចម្ការអ្នកភូមិឯទៀតៗ"។ អ្នកស្រីបានបន្ថែមថា កាលពីមុន គាត់មិនមានដាំអ្វីទាំងអស់នៅលើដីចម្ការរបស់គាត់ ព្រោះវាមានមីនច្រើនណាស់ ប៉ុន្តែឥឡូវវាមានសុវត្ថិភាពហើយ ដូចនេះគាត់អាចដាំចេក និងពោត ដើម្បីបង្កើនប្រាក់ចំណូលបន្ថែមទៀត។

បច្ចុប្បន្នអ្នកភូមិភាគច្រើននៅក្នុងភូមិនេះ អាស្រ័យលើចម្ការរបស់ខ្លួន ប៉ុន្តែផ្នែកខ្លះនៃផ្ទៃដីរបស់ពួកគេត្រូវបានគ្របដណ្តប់ដោយគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ដែលបានបន្សល់ទុកចាប់តាំងពីសង្គ្រាមស៊ីវិល ដែលអូសបន្លាយអស់ជាច្រើនទសវត្សរ៍។ ដោយគ្មានដីចម្ការធ្វើកសិកម្មអ្នកភូមិបានរស់នៅក្នុងស្ថានភាពលំបាកហើយពួកគាត់ភាគច្រើនជាមេគ្រួសារបានធ្វើចំណាកស្រុកពីកន្លែងមួយទៅកន្លែងមួយ ដើម្បីស្វែងរកការងារចិញ្ចឹមគ្រួសារ។

អ្នកស្រី ខឹម ដាលី អនុប្រធានភូមិតាថុកបាននិយាយថា "ខ្ញុំសប្បាយចិត្តណាស់ ដែលអ្នកភូមិរបស់ខ្ញុំបានដីមកវិញដោយលែងមានគ្រាប់មីន"។ អ្នកស្រីបានបញ្ជាក់ថា ដីដែលដោះមីនរួចហើយនេះអ្នកភូមិគាត់អាចដាំបន្លែ

តទៅទំព័រទី ២

Ta Thok village : Living in a village, a former battlefield between the government troops and the Khmer Rouge guerrillas, 46-year-old Chea Pho said she and other villagers now feel safe after their farming land has been de-mined.

Nearly everywhere in her village of Ta Thok located along a mountain foot is marked by landmine signs. A few years ago, a female villager who walked onto Chea Pho's farming field was killed by a mine. Then, Chea Pho and her family members never dared to walk onto their farming fields either until a group of deminers from the Cambodian Mine Action Center (CMAC) came to clear all type of mines and Unexploded Ordnance (UXO) left by the war.

"I am now so enjoying that my land is free from mines and nobody to be killed and wounded any more by mines on my land and other villagers' fields," said Chea Pho, the mother of three.

"Before, I could plan nothing on my fields because there were a lot of mines but now CMAC cleared them all so that I can grow banana and maize to gain m ore income," she added.

Most of the villagers in this village rely on their farming but some parts of their land plots were covered by mines and UXO since the country's long-decade civil war. With no any agricultural field, the villagers lived in hard condition and some of them, mostly the heads of the families, migrated from one place to another to find jobs to feed their families.

"I am happy that my villagers have their land back without mines," said Khem Daly, deputy chief of Ta Thok village. With the demined land, she said, her villagers can grow their vegetables, and other agricultural plants to make extra money and they have no more fear to get killed and wounded due to mines and UXO in the village.

According to her, among 646 villagers, six people, including a boy, and several cattle were wounded by landmines but since CMAC team has started their work in the village two years ago, there is no longer casualty.

CBMRRN has raised awareness, she said, on the danger of all types of mines and UXO among the villagers, especially the children who look after their cattle in the fields. "We have educated and explained to the villagers, school students and new comers on mine danger. We showed them the mine signs so that they know clearly where they can and cannot go in the village." she added.

According to ECOSORN report, 525 villagers and local authorities (161 persons in Battambang, 216 persons in Siem Reap, and 148 others in Banteay Meanchey) were selected to join Mine/UXO Committee (MUC) and they received training on Mine Risk Reduction Systems. It says the networks of MUC/CBMRRN have focused on the mine/UXO information gathering in ECOSORN target communes.

In 261 hectares of land in Ta Thok village is one of the target areas to be demined under ECOSORN, a three-year joint development project of the Royal Government of Cambodia and the European Commission. As a contractor of ECOSORN, CAMAC has to urgently clear mines in the land situated in the ECOSORN target areas which are known to be mine/UXO contaminated. All of mines and UXO were made in China, Vietnam, the former Soviet Union, and the US contaminated.

Rous Sideth, ECOSORN officialsbased in Battamabng, said all members of the networks play the key roles to ensure that all information on mines amd UXO has to be collected and passed

continued on page 4



គំរោងនេះប្រតិបត្តិដោយគំរោងអេកូសន និងផ្តល់មូលនិធិដោយសហភាពអឺរ៉ុប និងរាជរដ្ឋាភិបាលកម្ពុជា

# ដីសុវត្ថិភាពជីវិតសុខសាន្ត និង ...

## SAFE LAND, SAFE LIFE ...

និងដំណាំកសិកម្មផ្សេងៗ ដើម្បីរកប្រាក់ចំណូលបន្ថែម ហើយពួកគេលែងភ័យខ្លាចរឿងស្លាប់ និងរបួសដោយសារតែគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះទៀតហើយនៅក្នុងភូមិ។

អ្នកស្រីបានប្រាប់ឱ្យដឹងថានៅក្នុងចំណោមអ្នកភូមិចំនួន ៦៤៦ នាក់ នៅក្នុងភូមិមាន៦នាក់រួមទាំងក្មេងប្រុសម្នាក់ ផងនិងសត្វពាហនៈជាច្រើនទៀត បានរងរបួសដោយសារគ្រាប់មីន។ ប៉ុន្តែចាប់តាំងពីក្រុមស៊ីម៉ាក់បានចាប់ផ្តើមការងាររបស់គេនៅក្នុងភូមិអស់រយៈពេលពីរឆ្នាំកន្លងទៅនេះ គឺលែងមានគ្រោះថ្នាក់ទៀតហើយ។

អ្នកស្រីបានបញ្ជាក់ថា បណ្តាញកាត់បន្ថយគ្រោះថ្នាក់មីនតាមសហគមន៍បានបង្កើនការយល់ដឹងពីការគ្រោះថ្នាក់របស់មីននិងគ្រាប់មិនទាន់ផ្ទុះគ្រប់ប្រភេទដល់អ្នកភូមិ ពិសេសក្មេងដែលទៅឃ្វាលគោ។ អ្នកស្រីបានបន្ថែមថា "យើងបានអប់រំ និងពន្យល់ដល់អ្នកភូមិសិស្សសាលា និងអ្នកចំណូលថ្មី ពីបញ្ហាគ្រោះថ្នាក់ដោយសារគ្រាប់មីនព្រមទាំងបង្ហាញពួកពើស្លាកសញ្ញាមីន ដូចនេះ ពួកគេដឹងថាទីណា ដែលពួកគេអាចនិងមិនអាចទៅបាននៅក្នុងភូមិ "។



តាមរបាយការណ៍របស់គម្រោងអេកូសនបានឱ្យដឹងថាគំរោងអេកូសនស៊ីម៉ាក់បានជ្រើសរើសអ្នកភូមិ និងអាជ្ញាធរដែនដីចំនួន៥២៥នាក់(១៦១ នាក់ នៅខេត្តបាត់ដំបង ២១៦ នាក់ នៅសៀមរាប និង ១៤៨ នាក់ នៅបន្ទាយមានជ័យ) ឱ្យចូលរួមក្នុងគណៈកម្មាធិការមីន/គ្រាប់មិនទាន់ផ្ទុះ ហើយពួកគេទទួលបានការបណ្តុះបណ្តាលពីប្រព័ន្ធកាត់បន្ថយគ្រោះថ្នាក់មីន/គ្រាប់មិនទាន់ផ្ទុះ។ របាយ-ការណ៍បានបញ្ជាក់ថា បណ្តាញរបស់គណកម្មាធិការ គ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ ឬបណ្តាញកាត់បន្ថយគ្រោះថ្នាក់មីនតាមសហគមន៍នេះបានផ្តោតលើការប្រមូលព័តិមានស្តីពីមីន/គ្រាប់មិនទាន់ផ្ទុះនៅក្នុងបណ្តាឃុំគោលដៅរបស់គម្រោងអេកូសន។

រហូតមកដល់ពេលនេះគំរោងបានបោសសំអាតផ្ទៃដីមានគ្រាប់មីនចំនួន ២៦១ ហិកតា ក្នុងនោះភូមិតាថុក ក៏ជាភូមិមួយ ដែលស្ថិតនៅក្នុងចំណោមតំបន់គោលដៅជាច្រើន ដែលត្រូវបោសសំអាតមីន។ មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា (ស៊ីម៉ាក់) គឺជាអ្នកម៉ៅការរបស់គំរោងអេកូសន សំរាប់ផ្តល់សេវាកម្ម លើផ្នែកបោសសំអាតមីននៅក្នុងតំបន់គោលដៅរបស់គំរោងអេកូសន ដែលត្រូវបានគេគិតថាជាតំបន់ដែលរាយប៉ាយដោយគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ។ មន្ត្រីរបស់ស៊ីម៉ាក់ បានបញ្ជាក់ថា : គ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះដែលបានរកឃើញកន្លងមក គឺផលិតនៅប្រទេសចិន វៀតណាម អតីតសហភាពសូវៀត និងអាមេរិក។

លោក អាន ស៊ីដេត មន្ត្រីរបស់គម្រោងអេកូសន-ស៊ីម៉ាក់ទទួលបន្ទុកផ្នែកពង្រឹងសហគមន៍បាននិយាយថា សមាជិកទាំងអស់របស់បណ្តាញមីនស្ម័គ្រចិត្តគឺដើរតួនាទីសំខាន់ណាស់ ដើម្បីធានាថា រាល់ព័តិមានទាំងអស់ស្តីអំពីមីន និងគ្រាប់មិនទាន់ផ្ទុះត្រូវតែប្រមូលបានហើយផ្តល់ព័តិមានបន្តពីមួយទៅមួយ។ លោកបានបញ្ជាក់ថា ការអប់រំពី គ្រោះថ្នាក់ដោយសារគ្រាប់មីនតាមរយៈកម្មវិធីកាត់បន្ថយមីន តាមសហគមន៍ គឺជាការងារស្នូលនៅក្នុងចំណោមអ្នកភូមិ ខណៈដែលមានវីដេអូ និងខិតប័ណ្ណបានចាក់បញ្ចាំង និងចែកជូនដោយរួមទាំងមានយុទ្ធនាការតាមបណ្តាញព័តិមានទៀតផង។

បើតាមលោក ហម ខាន់ អ្នកជំនាញការរបស់គំរោងអេកូសន-ស៊ីម៉ាក់ ប្រចាំខេត្តបាត់ដំបង បានឱ្យដឹងថា ចម្ការមីនចំនួន ៤០ នៅក្នុងភូមិចំនួន ៣០ របស់ស្រុកពីរគឺស្រុកគាស់ក្រឡ និងស្រុកសំពៅលូនក្នុងខេត្តបាត់ដំបង គឺស្ថិតនៅក្រោមគម្រោងអេកូសន។ បើតាមផែនការរបស់គម្រោង គឺមានផ្ទៃដីសរុបចំនួន ៤០០ ហិកតា នៅក្នុងខេត្តទាំងបីរបស់គំរោងអេកូសនមានខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប គឺត្រូវបានជ្រើសរើសតាមរយៈគណៈកម្មាធិការកំចាត់មីនខេត្ត។

ហាច សារ៉េត អតីតយោធា អាយុ ៤៣ ឆ្នាំ ដែលជាអ្នកភូមិ ជាមួយអ្នកស្រី ជា ផូ ដែរនោះ ពិការជើងម្ខាង (ដាច់) ដោយសារជាន់គ្រាប់មីនកាលពីឆ្នាំ ១៩៨៥ បាននិយាយថា គាត់ជឿថា កូនៗទាំងបួនរបស់គាត់ និងអ្នកភូមិឯទៀតៗនឹងមិនទទួលរងគ្រោះថ្នាក់ពីមីនទៀតទេ។គាត់បាននិយាយដោយទឹកមុខ ញឹមៗថា "ខ្ញុំសប្បាយរីករាយណាស់ ដែលគម្រោងអេកូសន-ស៊ីម៉ាក់ បានបោសសំអាតគ្រាប់មីននៅក្នុងភូមិខ្ញុំ។ដូចនេះទាំងមនុស្សទាំងសត្វពាហនៈនឹងមិនស្លាប់ និងរបួសដោយសារគ្រាប់មីនទៀតទេ ហើយពួកយើងរីករាយនឹងការអភិវឌ្ឍនៅក្នុងសហគមន៍របស់យើង "។



អតីតយោធាពិការ ហាច សារ៉េត កំពុងកាប់ផ្ការចំការក្រោយសំអាតមីន

information from one to another. He said mine risk education through CBMRRN is the core subject among the villagers while video and leaflets were showed and distributed with a mass media campaign.

According to Horm Khann, CMAC key expert based in Battambang, 40 minefields in 30 villages of two districts, Koas Kralor and Sampou Loun, in Battambang province are under ECOSORN project. Based on the project plan, the total of 445.39 hectares of minefields in ECOSORN target areas of three province of Battambang, Banteay Meanchey and Siem Reap were selected through Provincial Mine Action Committees to be demined.

According to CMAC report posted on its website, the most damaging war of all was the war between 1970 and 1975 when 539,129 tons of air-to-ground bombs were dropped on Cambodia. It is estimated there are thousands of uneploded bombs still lying hidden underground. Starting in 1985, millions of mines were laid in a 600-kilometer barrier along the Thai border, it added.

However, through tireless efforts by the Royal Government with generous support and contributions from donor countries,CMAC has been able to free hazardous areas of mines and UXO in hundreds of square kilometres since 1993. According to its report, CMAC has found and destroyed over 181,659 anti-personnel mines; 3,514 antitank mines and 750,887 items of UXO, and cleared over 273,732,034 fragments.

43-year former soldier Hach Sareth, Chea Pho's neighbour who lost one leg due to stepping on a land mine in 1985 said he believes that his four children and other villagers will not get hurt from mines. "I am so happy that ECOSORN through CMAC has cleared mines in my village. So both human and cattle will not be killed and wounded by mines and we enjoy our development in our community," he said with smiling.

This project is implemented by ECOSORN and funded by the European Union and the Royal Government of Cambodia
The views expressed in this publication do not necessarily reflect the views of the European Union

# បំណិនជីវិត ជួយជីវភាពគ្រួសារ

# LIFE SKILL HELPS FAMILY

ភូមិមោងៈ តាមរយៈអ្នកម៉ៅការមួយក្នុងចំណោមអ្នកម៉ៅការជាច្រើនរបស់គម្រោងអេកូសន ស្ត្រីវ័យក្មេងម្នាក់អាចចូលរួមក្នុងវគ្គបណ្តុះបណ្តាលមួយពីការតុបតែងសម្ផស្សនៅក្នុងឃុំមោងឫស្សីនាងក្នុងខេត្តបាត់ដំបង។ បន្ទាប់ពីវគ្គរយៈពេល ៦ ខែមក ម៉ៅ ចរិយា អាយុ ២០ ឆ្នាំអាចគ្រប់គ្រងហាងតុបតែងសម្ផស្សតូចមួយដោយមានការគាំទ្រពីឪពុកម្តាយរបស់នាង។

កាលពីពីរឆ្នាំកន្លងទៅចរិយាបានស្នាក់នៅផ្ទះហើយមិនដឹង ថាតើរកស៊ីអ្វីនោះទេ បន្ទាប់ពីរៀនចប់វិទ្យាល័យ។ ថ្ងៃមួយនាងត្រូវបានប្រធានភូមិរបស់នាងមកជួប ហើយសួរថាតើនាងចង់ចូលរួមក្នុងវគ្គនេះដែលផ្តល់ដោយគម្រោងអេកូសនដែរឬក៏អត់។

ស្ត្រីវ័យក្មេងរូបនេះបាននិយាយថា"ខ្ញុំមិនមានលុយចូលរៀនមហាវិទ្យាល័យទេ ហើយខ្ញុំពិតជាមិនដឹងថាត្រូវធ្វើអ្វីនោះដែរ។ បន្ទាប់មកខ្ញុំមានអារម្មណ៏សប្បាយមែនទែន នៅពេលដែលប្រធានភូមិមកសួរខ្ញុំ ថាតើខ្ញុំអាចចូលរៀនវគ្គនោះឬអត់។ ខ្ញុំពិតជាចូលចិត្តមុខរបរនេះ ប៉ុន្តែខ្ញុំមិនអាចមានលុយគ្រប់ សម្រាប់រៀននៅឯសាលាឯកជននោះទេ។ ដូចនេះខ្ញុំមិនមានការអល់អែកក្នុងការឆ្លើយថា ខ្ញុំចង់រៀននោះដែរ"។

ការតុបតែងសម្ផស្សគឺជាផ្នែកមួយនៃបំណិនជីវិតផ្សេងៗគ្នាជាច្រើនដែលត្រូវបានផ្តល់តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈដោយគម្រោងអេកូសន ដែលជាគម្រោងរួមរបស់រាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុប។សិក្ខាកាមដែលត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ គឺជាអ្នកមានសក្តានុពល ដែលកំណត់ដោយប្រធានភូមិ និងសហគមន៏របស់ពួកគេ។

បើតាមផែនការ របស់គម្រោងមនុស្សប្រមាជា ១.៦៧០ នាក់នៅក្នុងតំបន់គោលដៅរបស់គម្រោងអេកូសនក្នុងខេត្តបីគឺបាត់ដំបងបន្ទាយមានជ័យនិងសៀមរាប ត្រូវបានជ្រើសរើសឱ្យក្លាយជាអ្នកទទួលផល ដែលមានសក្តានុពល។

លោក ឈឿន សុភាព អ្នកឯកទេសជាន់ខ្ពស់ផ្នែកសហគ្រិនរបស់គម្រោងអេកូសនបាននិយាយថា បើផ្អែកតាមគម្រោង គឺកំណត់ថា ៥០ ភាគរយនៃសិក្ខាកាមត្រូវតែជាស្ត្រី ខណៈដែលអ្នកខ្លះទៀតជាជនពិការ។ លោកបានបន្តថាគម្រោងមានបំណងថា យ៉ាងហោចណាស់ ៧០ ភាគរយនៃអ្នកទាំងឡាយដែលបានបញ្ចប់ការបណ្តុះបណ្តាលនឹងអាចមានការងារធ្វើ ហើយទទួលបានប្រាក់ចំណូលពី ២៥ដុល្លារ ទៅ ៣០ដុល្លារ។

សម្រាប់ ចរិយា បច្ចុប្បន្ននេះ នាងមានមុខរបរមួយដ៏ល្អនៅឯហាងតុបតែងសម្ផស្សរបស់នាងដោយមានកូនជាងជាស្ត្រីវ័យក្មេងដែលជាអ្នកជិតខាងរបស់នាង។ នាងបាននិយាយថា "ខ្ញុំមានអារម្មណ៏សប្បាយណាស់ដែលថា ខ្ញុំអាចទទួលបានមុខរបរមួយរបស់ខ្ញុំ បន្ទាប់ពីការបណ្តុះបណ្តាល។ ឥឡូវនេះ ខ្ញុំក៏មានមនុស្សពីរបីនាក់ដែរមករៀនជំនាញនេះពីខ្ញុំហើយពួកគេជួយការងារខ្ញុំខ្លះនៅពេលមានភ្ញៀវច្រើនមកតុបតែងខ្លួននៅពេលតែមួយ"។

ចរិយា ចេះកាត់សក់ អប់សក់ស្ត្រី និងបុរស ចេះផាត់មុខ បកស្បែក និងធ្វើក្រចក ហើយទាំងអស់នេះគឺនាងបានចេះពីការចូលរៀនក្នុងវគ្គបណ្តុះបណ្តាលដែលផ្តល់ដោយគម្រោងអេកូសន។



កញ្ញា ម៉ៅ ចរិយា កំពុងបង្ហាត់បង្ហាញកូនជាងតុបតែងមុខ

Moang Village : Through one of ECOSORN contractors, a young woman could join a training courseon beauty making in her commune of Moang Russei of Battambang province. After six-month course, Mao Chakrya, 20, has been able to run a small beauty parlor with support from her parents.

Two years ago, Chakrya stayed at home and did not know what to makeabusinessafterfinishinghigh school.Onedayshewasreachedby her village chief and asked if she wanted to participate in the training offered by ECOSORN.

"I cannot afford for a faculty and I really did not know what to do. Then, I felt quite happy when thevillage chief asked me if I could join the training. I really like this business but I could not afford for studying at a private shop. So, I had no hesitation to say yes I wanted," the young lady said with smiling.

Beauty making is one of several different life skills provided through vocational trainings by ECOSORN, a joint project of the Royal Government of Cambodia and the European Commission. The trainees selected to join the trainings were the potential people identified by their chiefs of villages and communities.

According to the project plan, some 1,670 people in ECOSORN's target areas of three provinces of Battambang, Banteay Meanchey, and Siem Reap must be selected as the pilot beneficiates.

Chhoeun Sopheap, ECOSORN's Senior Enterprise Specialist, said that based on the project up 50 percent of the trainees must be women while some others are disabled people. The project aims that at least 70 percent of those who finished the training would be able to have their employment and get income between US$25 and US$30, he said.

For Chakrya, she has now a good business at her beauty parlor with four young female attendants who are her neighbours. "I feel very happy that I can get my business after the training. I now also have a few people to learn on the skill from me and they help me with some work when more clients come at the same time to make their beauty," she said.

Chakrya can dress both women's and men' hairs, face making up, and beautify nails and all of theses she learn from the training course.

# បង្គន់អនាម័យ នៅតាម សហគមន៍

# HYGIENE TOILET IN COMMUNITIES

ភូមិបាល័្លង្គមានជ័យ : អស់រយៈពេល ៣៣ ឆ្នាំមកនេះ ស្រ្តីជាម្តាយរបស់កូនបីនាក់មិនដែលប្រើបង្គន់ណាមួយឡើយ។ បង្គន់ធម្មជាតិរបស់គាត់ គឺទីកន្លែងមួយ ដែលនៅចម្ងាយម្ភៃសាបសិបម៉ែត្រពីខាងក្រោយផ្ទះរបស់ខ្លួន។ ជារៀងរាល់ថ្ងៃអ្នកគ្រប់ៗគ្នានៅក្នុងផ្ទះបានទៅទីនោះ នៅពេលដែលពួកគេចង់បន្ទោរបង់ ហើយពួកគេបត់ជើងតូចនៅតែ ប៉ុន្មានម៉ែត្រពីផ្ទះប៉ុណ្ណោះ។

ប៉ុន្តែកាលពីពីរបីខែកន្លងទៅនេះ អ្នកស្រី បូ ផារី ស្ថិតក្នុងវ័យ ៣៣ ឆ្នាំ មានបង្គន់អនាម័យមួយ ដែលសង់នៅក្បែរផ្ទះប្រមាណជាពីរបីម៉ែត្រ។ បង្គន់នេះត្រូវបានផ្តល់ឱ្យដោយគម្រោងអេកូសន ដែលជាគម្រោងភិវឌ្ឍន៍រួមរវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុប។

អ្នកស្រីបាននិយាយដោយមានទឹកមុខអឹមអៀនថា "ខ្ញុំមិនដែលប្រើបង្គន់បែបហ្នឹងទេក្នុងរយៈពេលជាង ៣០ ឆ្នាំមកនេះហើយខ្ញុំក៏មិនដែលបានឃើញពុកម៉ែ និងជីដូនជីតាខ្ញុំបានប្រើវាដែរកាលពីមុនប៉ុន្តែឥឡូវខ្ញុំបានប្រើវាហើយ។ វាពិតជាពិបាកប្រើពីដំបូង ប៉ុន្តែឥឡូវនេះវាស្រួលមែន"។

មិនមែនតែគ្រួសាររបស់អ្នកស្រី បូ ផារី នោះទេ ប៉ុន្តែជាង ៣០ គ្រួសារផ្សេងទៀតនៅក្នុភូមិបាល័្លង្គមានជ័យក៏បានទទួលបង្គន់ដូចគ្នាដែរ ក្នុងមួយគ្រួសារៗ។ ពួកគេគឺជាគ្រួសារដែលត្រូវបានជ្រើសរើសក្នុងចំណោមអ្នកភូមិដើម្បីឱ្យធ្វើជាកសិករគំរូនៅក្នុងភូមិ។

បើតាមការបញ្ជាក់របស់លោក ជុំ ស៊ន មេភូមិបាល័្លង្គមានជ័យបានឱ្យដឹងថា ៣៣ គ្រួសារ ក្នុងចំណោមកសិករទាំង ១០៣ គ្រួសារ នៅក្នុងភូមិកាលពីពេលថ្មីៗនេះបានទទួលបង្គន់ពីគម្រោងអេកូសន។ លោកបាននិយាយថា "ខ្ញុំគិតថាវាល្អណាស់ដែលមានបង្គន់នេះសម្រាប់ភូមិរបស់ខ្ញុំ ដូច្នេះពួកគេមានអនាម័យ និងចៀសផុតពីជំងឺដង្កាត់ផ្សេងៗដូចជាជំងឺសើរស្បែក និងជំងឺរាគរូសជាដើម "។

ការផ្តល់បង្គន់ដល់កសិករគឺជាផ្នែកមួយនៃគម្រោងអេកូសន ដើម្បីជួយធ្វើឱ្យសុខភាពរបស់ប្រជាពលរដ្ឋនៅឯមូលដ្ឋានបានកាន់តែប្រសើរឡើង។ គម្រោងអេកូសនបានផ្តល់បង្គន់អនាម័យចំនួន ៦,២២៣ ដល់អ្នកភូមិនៅក្នុងតំបន់គោលដៅរបស់ខ្លួនក្នុងខេត្តបីគឺបាត់ដំបង បន្ទាយមានជ័យ និងសៀមរាបហើយតាមរយៈអ្នក ម៉ៅការរបស់ខ្លួន គម្រោងក៏បានផ្តល់ការអប់រំទូទៅពីបញ្ហាសុខភាពព័ត៌មានស្តីពីការបង្កាជំងឺ និងការរស់នៅប្រកបដោយអនាម័យល្អ ពិសេសការប្រើប្រាស់បង្គន់អនាម័យ។

អ្នកស្រី បូ ផារី បាននិយាយដោយផ្ទះសំណើចថា "ខ្ញុំគិតថាអ្នកភូមិផ្សេងទៀតក៏ចង់មានបង្គន់អនាម័យនេះដែរ ព្រោះបើមានបង្គន់អនាម័យ ពួកគេលែងទៅបន្ទោរបង់ក្នុងព្រៃទៀតហើយ។ ក្រោយពីមានបង្គន់នេះមកបងប្រុសរបស់ខ្ញុំដែលរស់នៅក្បែរគ្នានេះក៏សម្រេចសង់បង្គន់ដោយខ្លួនគាត់មួយដែរសម្រាប់ការប្រើប្រាស់របស់គ្រួសារគាត់ "។



មានបង្គន់អនាម័យងាយស្រួលក្នុងការប្រើប្រាស់



មានបង្គន់អនាម័យ មានសុខភាពល្អ

Balaing Meanchey Village : For 33 years, a mother of three children never used any toilet. Her natural toilet was a space, a few dozens meters behind the house. Everyday, everyone in the house went to that place when they wanted to pass stool and they pissed a few meters away from the house.

But a few months ago, 33 year-old Bo Phary has had a hygiene toilet built in a few meters away from her house. The toilet was provided by ECOSORN, a joint development project of the Royal Government of Cambodia and the European Commission.

"I never used such toilet for more than 30 years and I never saw my parents and great parents used it as well before but I now use it. It was really hard to use it at the beginning but now it is easy. I think using the toilet is much more sanitary than the place behind the house," she said with a bit shy-looking face.

Not only Bo Phary's family but also more than 30 other families in Balaing Meanchey village also got the same toilet each. They are the selected families among the villagers to be the pilot farmers in the village.

According to Chief of Balaing Meanchey village Chum Soun, 33 out of 103 families in the village have recently received the toilet from ECOSORN. "I think it is very good to have the toilet for my villagers, so that they have sanitation and avoid diseases such as skin disease and diarrhea," he said.

Providing toilets to farmers is part of the project to help improve health condition of the citizens at the grassroots. ECOSORN has provided 1.211 hygiene toilets to the villagers in its target areas of the three provinces of Battambang, Banteay Meanchey, and Siem Reap and through its contractors, ECOSORN also provided general education on health issue, information on prevention of diseases, and healthy lifestyle, especially using hygiene toilet.

"I think other villagers also want to have such hygiene toilet because when they have hygiene toilet they stop going to drop in the forest. After I have had the toilet, my brother living nearby also decided to build a toilet by his own for his family's use," said Bo Phary with laughing.



This project is implemented by ECOSORN and funded by the European Union and the Royal Government of Cambodia
The views expressed in this publication do not necessarily reflect the views of the European Union

# ថែរក្សាប្រឡាយទឹក ដើម្បី ជីវភាពប្រចាំថ្ងៃ

# CANAL MAINTENANCE FOR DAILY LIFE

ភូមិព្រៃសង្ហា: ខុសប្លែកពីកសិករភាគច្រើននៅក្នុងភូមិ គ្រួសាររបស់ ចាម រិត គឺជាអ្នកភូមិដែលត្រូវការគម្រោងអេកូសនជ្រើសរើសជាកសិករគំរូជាមួយអ្នកភូមិមួយចំនួនទៀត ដើម្បីទទួលផលពីប្រឡាយទឹក។

ស្ថិតក្នុងវ័យ ៥៦ ឆ្នាំ បុរសដែលមានកូនក្នុងបន្ទុកចំនួន ៤ នាក់រូបនេះ បាននិយាយដោយទឹកមុខស្រស់ស្រាយថា "បើអត់ប្រឡាយទឹកនេះទេគឺពិតជាយ៉ាប់ហើយ"។

លោក រិត ដែលជាប្រធានក្រុមប្រើប្រាស់ទឹកប្រចាំភូមិដែរនោះបានបញ្ជាក់ថា ដោយសារតែប្រឡាយទឹកនេះហើយទើបឱ្យកសិករគំរូ និងកសិករផ្សេងទៀតនៅក្នុងភូមិអាចមានទឹកធ្វើស្រែបានពីររដូវ ដែលប្រការនេះបានធ្វើឱ្យជីវភាពរបស់ពួកគេបានធូរធារជាងមុនច្រើន។

ការផ្ដល់ប្រឡាយទឹក គឺជាផ្នែកមួយនៃការអភិវឌ្ឍសហគមន៍មូលដ្ឋានរបស់គម្រោងអេកូសន។ ប្រឡាយទឹកនេះគឺជាការស្ដារប្រព័ន្ធធារាសាស្ត្រខ្នាតតូចជួយដល់កសិករគំរូនៅក្នុងតំបន់គោលដៅទាំងបីខេត្ត គឺខេត្តបាត់ដំបងខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាបរបស់គម្រោងអេកូសន។

លោកស្រី សុខ សុ ជាតា មន្ត្រីទ្រទ្រង់ប្រើប្រាស់ទឹករបស់អេកូសនប្រចាំខេត្តបាត់ដំបងបាននិយាយថា ក្រៅពីប្រឡាយចាស់ៗនៅក្នុងភូមិគោលដៅត្រូវបានស្ដារឡើងវិញដោយគម្រោង គម្រោងក៏បានជួយបណ្ដុះបណ្ដាលអ្នកភូមិពីការងារបច្ចេកទេសមួយចំនួន ដូចជាដំណើរការប្រើប្រាស់ទឹកឱ្យបានសមស្របការថែទាំ និងការជួសជុលប្រឡាយ និងការគ្រប់គ្រងសហគមន៍ប្រើប្រាស់ទឹក ដើម្បីរក្សានិរន្តរភាពរបស់ប្រឡាយទៅថ្ងៃអនាគត។

លោកស្រីបានលើកឡើងថា វាជាការចាំបាច់បំផុតសម្រាប់កសិករក្នុងការថែទាំប្រឡាយទឹកឱ្យបានល្អនៅពេលដែលគម្រោងនឹងបញ្ចប់នៅចុងឆ្នាំ ២០១០ នេះ។

លោកស្រីក៏បន្ថែមដែរថា "គម្រោងបានបណ្ដុះបណ្ដាលកសិករពីការគ្រប់គ្រង ប្រាក់ចំណូលដែលបង់ដោយសមាជិកក្រុមប្រើប្រាស់ទឹក ដើម្បីរក្សាទុកជួសជុលប្រឡាយ ហើយគម្រោងក៏បានជួយបើកគណនីធនាគារឱ្យពួកគេសម្រាប់រក្សាប្រាក់ចំណូលទាំងនោះដែរ"។

លោកបាននិយាយដោយទឹកមុខញញឹមៗថា "ខ្ញុំគិតថាមិនមែនតែគ្រួសារខ្ញុំនោះទេ គឺសមាជិកគ្រួសារអ្នកប្រើប្រាស់ទឹកឯទៀតក៏មានជីវភាពគ្រាន់បើជាងមុនដែរ ព្រោះពួកគេធ្វើស្រែបានពីរដងក្នុងមួយឆ្នាំ។ ដូចនេះពួកយើងគិតថាប្រឡាយទឹកដែលគម្រោងអេកូសនផ្ដល់ឱ្យនេះ គឺជាដង្ហើមនៃជីវភាពរបស់យើងប្រចាំថ្ងៃ។ ដោយសារប្រឡាយនេះយើងក៏អាចដាំបន្លែបង្ការ និងទុកឱ្យសត្វពាហនៈបានផឹកដែរនៅក្នុងរដូវប្រាំង"។

លោកបានបន្តថា ដោយសារតែមើលឃើញពីសារៈសំខាន់នៃប្រឡាយនេះហើយទើសមាជិកក្រុមប្រើប្រាស់ទឹកនៅក្នុងភូមិរបស់លោកបានប្ដេជ្ញាថែរក្សាប្រឡាយនេះឱ្យមាននិរន្តរភាព ហើយថា "យើងមិនចង់ឱ្យគម្រោងចប់ ប្រឡាយខូចនោះទេ ព្រោះការថែរក្សាប្រឡាយទឹកគឺជាការទ្រទ្រង់ជីវភាពរបស់យើងប្រចាំថ្ងៃ"។

គួរបញ្ជាក់ដែរថានៅខេត្តបាត់ដំបង គម្រោងអេកូសនបានផ្ដល់ប្រឡាយមេចំនួនបីដែលស្ថិតនៅក្នុងពីរស្រុក គឺស្រុកបវេលចំនួន ២ ប្រវែងជា៨,៨៨០គីឡូម៉ែត្រនិងស្រុកមោងចំនួន ១ ប្រវែង ៤,៨៥៧ គីឡូម៉ែត្រដែលអាចស្រោចស្រពលើដីស្រែសរុបចំនួន ១,៤០៨ ហិកតា នេះ បើតាមការអះអាងរបស់ លោក ប៊ុន នាងសុនន្ទ វិស្វករហេដ្ឋារចនាសម្ព័ន្ធជនបទរបស់គម្រោងអេកូសនប្រចាំខេត្តបាត់ដំបងប្រព័ន្ធធារាសាស្ត្រចំនួន ៩ កន្លែង ត្រូវបានសាងសង់ដោយគម្រោងអេកូសននៅក្នុងខេត្តគោលដៅទាំងបី គឺបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប។



ប្រឡាយទឹក គឺជាអាយុជីវិតរបស់កសិករ

Prey Sangha Village: Different from most farmers in the village, Cham Rith's family has been selected among others as the pilot farmers by ECOSORN project to gain benefit from a canal.

In 56 years of age, the father of four said with fresh-looking that "Without this canal, we are really difficult,".

Rith who is also the head of Water Use Group in the village said that because of the canal the pilot farmers and others in the village can get water for rice plantation twice a year which is more improving their living condition.

Providing canal is part of local community development of ECOSORN, a joint development project of the Royal Government of Cambodia and the European Union. The canal is the small irrigation rehabilitation schemes to help the pilot farmers in the ECOSORN's target areas in three provinces of Battambang, Banteay Meanchey, and Siem Reap.

Sok Socheata, ECOSORN's Water Use Support Officer based in Battambang, said that besides the rehabilitation of the old canals in the target villages, the project also trained the villagers on some technical works like : using appropriate water in the canals, maintaining and repairing the canals, and water use community management in order to keep sustai-nability of the canals in the future.

She said it is most important for the farmers to maintain the canals properly after the project finishes by the end of 2010.

"The project has trained the farmers on ma-nagement of incomes paid by members of the Water Use Groups to keep for repairing the canals and the project has also helped open their bank accountsto keep the incomes," she added.

"I think that not only my family but other members of the Warder Use Group also have better living conditions because they have done the rice plantation twice a year. So we think that the canal provided by ECOSORN project is the breath of our daily lives. Because of this canal, we are also able to plan other vegetables and keep for our cattle in the dried season," he said with smiling.

He added that because of seeing the importance of canal, the members of the Warder Use Group in his village have made their commitment to maintain the canal sustainability and that "we do not want to project end and the canal is damaged at the same time because the canal maintenance is supporting our daily lives".

ECOSORN project has provided three scheme of canals in Battambang in two districts : 2 schemes in Bavel district with 8,880 km and 1 scheme in Maung Russei district with 4.857 km covering on the total land of 1,408 hectares, mentioned by Mr. Bun neang Sonant, Rural Infrastructure Engineer based in Battambang. Nine irrigation schemes have been constructed by the project in the target areas in three provinces of Battambang, Banteay Meanchey, and Siem Reap.



គំរោងនេះប្រតិបត្តិដោយគំរោងអេកូសន និងផ្ដល់មូលនិធិដោយសហភាពអឺរ៉ុប និងរាជរដ្ឋាភិបាលកម្ពុជា

# សិក្ខាសាលាប្រចាំឆ្នាំពិនិត្យមើលលើ សមិទ្ធផល និង ការរៀបចំផែនការថ្មី នៅបាត់ដំបង

## ANNUAL WORKSHOP TO OVERVIEW ACHIEVEMENTS AND NEW PLANNING IN BATTAMBANG

ក្រុងបាត់ដំបង : ដើម្បីធ្វើឱ្យគុណភាពការងាររបស់ខ្លួនឱ្យកាន់តែប្រសើរឡើងនៅក្នុងឆ្នាំ ២០១០ និងដើម្បីជាប្រយោជន៍របស់ប្រជាពលរដ្ឋ ដែលស្ថិតនៅក្នុងគម្រោងផង និងមិនស្ថិតនៅក្នុងគម្រោងផងក្នុងតំបន់គោលដៅរបស់អេកូសនលើទឹកដីខេត្តបាត់ដំបង ការិយាល័យអេកូសនប្រចាំខេត្តបាត់ដំបង បានរៀបចំសិក្ខាសាលាមួយដែលមានរយៈពេលពីរថ្ងៃ។

ថ្លែងនៅក្នុងសុន្ទរកថាបើកកម្មវិធីលោក ប៉ោ ប្រង់ នាយកខុទ្ទកាល័យសាលាខេត្តបាត់ដំបងបានមានប្រសាសន៍ថា ក្នុងនាអាជ្ញាធរខេត្ត លោកមានមោទនភាព និងកោតសរសើរក្រៃលែង ដែលក្រុមការងារអនុវត្តគម្រោងរបស់អេកូសន បានបំពេញការងារយ៉ាងសស្រាក់សស្រាំ ហើយសម្រេចបាននូវសមិទ្ធផលដ៏ធំធេងនៅក្នុង ផ្នែកទាំងប្រាំរបស់ខ្លួនដែលក្នុងនោះរួមមាន : ១. ការធ្វើប្រពលវប្បកម្ម ពិពិធកម្មកម្ម និង បង្កើនផលិតកម្ម កសិកម្ម បសុសត្វ និង ជលផល។ ២. ការបង្កើតកាលានុវត្តភាព សេដ្ឋកិច្ច និងឱកាសការងារ។ ៣. ការផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន។ ៤. ការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពប្រើប្រាស់សេវាកម្មជារូបវន្តទីផ្សារ និងទឹកស្អាត។ ៥. ការប្រើប្រាស់ដីធ្លីសម្រាប់ដាំដុះ និងហេដ្ឋារចនាសម្ព័ន្ធសង្គមប្រកបដោយសុវត្ថិភាព និងជាអចិន្ត្រៃយ៍។

សិក្ខាសាលាស្តីពីការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០០៩ និងលើកទិសដៅបន្តឆ្នាំ ២០១០ នេះត្រូវបានចូលរួមដោយមន្ត្រីអេកូសន អ្នកម៉ៅការនិងមន្ត្រីមកពីស្ថាប័នពាក់ព័ន្ធជិត ១៤០នាក់។ អ្នកចូលរួមបានពិភាក្សាគ្នាពីសមិទ្ធផល និងការប្រឈមក្នុងការងាររយៈពេលមួយឆ្នាំកន្លងមកហើយស្វែងរកដំណោះស្រាយនៅក្នុងឃុំគោលដៅទាំង ១៣ របស់ស្រុកចំនួន ៦ គឺស្រុកមោងឫស្សី បវេល គាស់ក្រឡ រតនៈមណ្ឌល សំពៅលូន និងស្រុករុក្ខគិរី ក្នុងខេត្តបាត់ដំបង ដើម្បីភាពខ្លាំង និងរកភាពខ្សោយសម្រាប់ប្រសិទ្ធភាពការងារនាឆ្នាំ ២០១០។

បើតាមលទ្ធផលរបស់សិក្ខាសាលាបានបង្ហាញថាគម្រោងបីឆ្នាំពិតជាបានឆ្លើយតបទៅនឹងតម្រូវការរបស់កសិករហើយក្រុមការងាររបស់អេកូសននឹងខិតខំពង្រឹង សមត្ថភាព ដើម្បីបន្តការងារឱ្យមាននិរន្តភាពសម្រាប់ពេល ខាងមុខ។

Battambang city : To improve its quality of work in 2010 for the interests of the citizens who are both the project beneficiaries and non-beneficiaries in ECOSORN target areas of Battambang province, ECOSORN Battambang office conducted a two-day workshop. Speaking in his open remarks, Chief of Battambang Provencal Cabinet Por Prang said that on behalf of the provincial authority, he felt very proud and much appreciated that all ECOSORN teams have actively worked and accomplished the huge achievements in the five planned fields in which there are (1) Agricultural, Livestock, and Fishery Production Intensified, Diversity and Increased; (2) Economic and Employment Opportunities Developed; (3) Empowerment of Local Communities; (4) Improved Physical Access to Available Social Amenities and Market, Greater Access to potable Water Supplies; (5) Safer and Permanent Access to Arable Land and Social Infrastructures.

The workshop on annual achievements in 2009 and next plan in 2010 was participated by nearly 140 ECOSORN staff, ECOSORN's contractors, and other representatives from institutions concerned. The participants discussed their past achievements and challenges during the one-year work, and find solutions in the 13 target communes of six districts of Moang Russei, Bovel, Koas Kralor, Ratnak Modoul, Sampoav Loun, and Rokakirri in Batambang provinceto find out their strength and weakness for effective in implementation in year of 2010.

According to the workshop results, the three-year project has really responded to the farmers' needs and the ECOSORN team is more trying to strengthen capacity for sustainable work in all fields for the future.

**Technical Assistance Provided By www.vakakis.gr**


**ការិយាល័យកម្មវិធី និងគំរោងខេត្តសៀមរាប**
**Programme and Project Office, Siem Reap**
Provincial Department of Agriculture
Wat Damnak Salakamroek, Siem Reap, Siem Reap Province
P.O Box : 93241 Siem Reap Angkor
Tel : 063 965 478 - Fax : 063 761 243
Email : siem.reap.office@ecosorn.org
**website : www.ecosorn.org**

**ការិយាល័យគំរោងខេត្តបាត់ដំបង**
**Project Office, Battambang**
Provincial Department of Agriculture
National Road No.10, Damnak Luong, Wat Kor
Battambang, Battambang Province
P.O. Box : 404 BB
Tel : 053 953 534 - Fax : 053 730 398
Email : battambang.office@ecosorn.org

**ការិយាល័យគំរោងខេត្តបន្ទាយមានជ័យ**
**Project Office, Banteay Meanchey**
Provincial Department of Agriculture
Village II, Kampong Svay, Sereysophorn, Banteay Meanchey Province
Tel/Fax : 054 710 344 - P.O Box : 105 Banteay Meanchey
Email : banteay.meanchey.office@ecosorn.org

**ការិយាល័យសម្របសម្រួលភ្នំពេញ**
**Coordination Office, Phnom Penh**
Ministry of Agriculture, Forestry and Fisheries
#200, Norodom Blvd, Chamkarmon, Phnom Penh
Suite : #19-21, AIDOC building - Tel/Fax : 023 223 786
Email : phnom.penh.office@ecosorn.org


**គណៈកម្មាធិការដឹកនាំគំរោង**
Project Steering Committee

MAFF | MRD | MOWRAM | MOI | MOWA | MLMUPC


This project is implemented by ECOSORN and funded by the European Union and the Royal Government of Cambodia
The views expressed in this publication do not necessarily reflect the views of the European Union